**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King


ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation


លេខៈ ៥៨៩ ឧវបក ខល សណល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើកទី៤ ឆ្នាំ២០២៦

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងរៀបចំ **ទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ពីថ្ងៃទី២៦ ដល់ ២៨ ខែមីនា ឆ្នាំ២០២៦** នៅមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ក្នុងរាជធានីភ្នំពេញ ក្រោម អធិបតីភាព **ឯកឧត្តម វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

**ទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២៦** នឹងប្រារព្ធធ្វើឡើងក្រោមប្រធានបទ **«នវានុវត្តន៍ដើម្បីវឌ្ឍនភាពជាតិ»** ក្នុងគោលបំណងផ្សព្វផ្សាយ ពង្រីកការយល់ដឹងអំពីសមិទ្ធផល ការវិវត្តជឿនលឿន និងចក្ខុវិស័យផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍របស់កម្ពុជា សំដៅគាំទ្រការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។

ទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើកទី៤ នឹងមានកម្មវិធីសំខាន់ៗចំនួន ៦ ដូចខាងក្រោមៈ

(១) ពិព័រណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
(២) វេទិកាជជែកពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
(៣) សកម្មភាពជំរុញនវានុវត្តន៍
(៤) កម្មវិធីប្រកួតប្រជែងពានរង្វាន់វិទ្យាសាស្ត្រ ឆ្នាំ២០២៦
(៥) ពិធីប្រគល់ពានរង្វាន់ «អ្នកវិទ្យាសាស្ត្រកម្ពុជាឆ្នើម»
(៦) ពិធីប្រគល់ពានរង្វាន់នវានុវត្តន៍សម្រាប់វិស័យសាធារណៈ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សូមគោរពអញ្ជើញសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី តំណាងសហគមន៍ធុរកិច្ច អ្នកស្រាវជ្រាវ អ្នកវិទ្យាសាស្ត្រ នវានុវត្តន៍ករ សិស្សនិស្សិត និងសាធារណជន ចូលរួមទិវាជាតិនេះឱ្យបានច្រើនកុះករ។ ក្រសួងក៏លើកទឹកចិត្តដល់ក្រុមហ៊ុនបច្ចេកវិទ្យា ក្រុមហ៊ុនក្នុងវិស័យថាមពល កែច្នៃអាហារ ផលិតឧបករណ៍ គ្រឿងបន្លាស់ គ្រឿងបង្គុំមេកានិច និងអេឡិចត្រូនិច ក្រុមហ៊ុនផ្តល់ដំណោះស្រាយឌីជីថល និងសេវាហិរញ្ញវត្ថុ ឱ្យចូលរួមតាំងពិព័រណ៍ ស្វែងយល់ពីសក្តានុពល និងឱកាសសម្រាប់កិច្ចសហប្រតិបត្តិការ និងកំណើនដែលជំរុញដោយនវានុវត្តន៍។ss

ថ្ងៃ សុក្រ ១២កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២៦